**មតិសំណេះសំណាល**

**របស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី**

**និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**ក្នុងឱកាសប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន**

**ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧**

*-សូមក្រាបថ្វាយបង្គំព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គ ជាទីសក្ការៈ*

*-ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជនរួមជាតិ*

*-ក្មួយៗ យុវជន យុវនារី កុមារា កុមារី ជាទីមេត្រី*

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយឥតឧបមា ដែលមានឱកាសជាថ្មីម្តងទៀតបានមកថ្វាយបង្គំ ព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គ បានមកជួបឯកឧត្តម អស់លោក លោកស្រី ជាមន្ត្រីរាជការ កងកំលាំង ប្រដាប់អាវុធ បងប្អូនជនរួមជាតិ ជាអាជីវករ កសិករ កម្មករ និង ក្មួយៗសិស្សានុសិស្ស នៅក្នុងខេត្ត បាត់ដំបង ក្នុងឱកាសទិវាអន្តរជាតិប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់ និង ការចរាចរគ្រឿងញៀនខុសច្បាប់ថ្ងៃទី ២៦មិថុនា ឆ្នាំ ២០០៧ ។

ខ្ញុំក៏សូមយកឱកាសដ៏ថ្លៃថ្លានេះដើម្បីស្វាគមន៏យ៉ាងកក់ក្តៅចំពោះភ្ញៀវជាតិ និងអន្តរជាតិដែលអញ្ជើញមកពីភ្នំពេញ និងមកពីបណ្តាខេត្ត-ក្រុងនានា ដើម្បីចូលរួមក្នុងពិធីដ៏អធិកអធមថ្ងៃនេះ។ ជាការពិតនៅតាមបណ្តាខេត្ត-ក្រុង ផ្សេងៗក៏បានចាត់តាំងរៀបចំពិធីរបៀបនេះដែរ តែវាខុសគ្នាត្រង់ថាឆ្នាំនេះខេត្តបាត់ដំបង ត្រូវបានយើងជ្រើសរើសសំរាប់រៀបចំពិធីនេះថ្នាក់ជាតិ ហើយការជ្រើសរើសយកខេត្តបាត់ដំបងដើម្បីរៀបចំពិធីនេះក៏មិនមែនជាការចៃដន្យឡើយ។ កន្លងទៅនេះអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដាក់ចេញនូវគោលការណ៏ណែនាំសំរាប់អនុវត្តផែនការប្រៀបសមរភូមិ ដើម្បីសំដៅធ្វើអោយសហគមន៏ទាំងមូលគ្មានគ្រឿងញៀន ។ យើងបានជ្រើសរើសខេត្តបាត់ដំបងធ្វើជាខេត្តសំរាប់ដកពិសោធន៏ក្នុងការអនុវត្តផែនការនេះ ។

ខ្ញុំសូមកោតសរសើចំពោះអាជ្ញាធរខេត្ត ចំពោះសមិទ្ធិផលនានាដែលខេត្តទទួលបានក្នុងការអនុវត្តបំពេញការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចជាថែរក្សាសណ្តាប់ធ្នាប់ និង សន្តិសុខជូនប្រជាពលរដ្ឋ និងសង្គមជាតិ ។ ជារួមយើងពិនិត្យឃើញមានការវិវត្តន៍ច្រើនពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន ។ ប៉ុន្មានឆ្នាំមុននេះប្រទេសកម្ពុជាយើងគ្រាន់តែជាប្រទេសដែលរងគ្រោះដោយសារគ្រឿងញៀនឆ្លងកាត់ និង រងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនប៉ុណ្ណោះ តែឥឡូវនេះនិន្នាការមានការប្រែប្រួលគួរអោយកត់សំគាល់ ។ នៅពេលដែលយើងខិតខំទប់ស្កាត់ការចរាចរគ្រឿងញៀននៅតាមតំបន់ព្រំដែនចូលមកប្រទេសយើង វាបែរជាមានការផលិតកែច្នៃគ្រឿងញៀនក្នុងស្រុកដើម្បីយកមកប្រើប្រាស់ទៅវិញ ។ មិនតែប៉ុណ្ណោះថ្មីៗនេះមានការនាំសំភារៈឧបករណ៍ទំនើបៗ សារធាតុគីមីផ្សំ និង អ្នកគីមីមកផលិតគ្រឿងញៀននៅក្នុងប្រទេសយើងតែម្តង។ យើងមិនមានចេតនាចង់បន្ទោសទៅលើសមត្ថកិច្ចណាមួយទេ តែយើងត្រូវតែសិក្សាអោយបានស៊ីជំរៅដល់ឬសគល់ពីមូលហេតុដែលនាំអោយសភាពការណ៍វាវិវត្តន៍ទៅយ៉ាងនេះ ។

*ព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រី ក្មួយៗទាំងអស់ជាទីមេត្រី*

ឥឡូវនេះ យើងងាកមកនិយាយអំពីប្រធានបទរបស់យើងនៅថ្ងៃនេះវិញ ។ ដូចដែលខ្ញុំបានជំរាបជូនក្នុងសារលិខិតរបស់ខ្ញុំដែលបានផ្សព្វផ្សាយតាមបណ្តាញពត៌មាននានារួចមកហើយថា ឆ្នាំនេះអង្គការសហប្រជាជាតិបានសំរេចយកប្រធានបទសំរាប់ថ្ងៃទី ២៦ មិថុនា ឆ្នាំ ២០០៧ នេះគឺ "**តើគ្រឿងញៀនត្រួតត្រាជីវិតអ្នកឬ?**" ដែលតាមន័យនេះ ការិយាល័យគ្រឿងញៀន និង ឧក្រិដ្ឋកម្មរបស់អង្គការសហប្រជាជាតិ (យូ.អ៊ិន.អូ.ឌី.ស៊ី) បានកំណត់ពាក្យស្លោកមួយថា "**ជីវិតយើង សហគមន៍យើង គ្មានគ្រឿងញៀន** "។

ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះពាក្យពេចន៍ដែលយកមកប្រើប្រាស់សំរាប់ទិវាអន្តរជាតិនៅក្នុងឆ្នាំនេះ ។ **តើគ្រឿងញៀនត្រួតត្រាជីវិតអ្នកឬ?** ជាធម្មតា គ្មាននរណាម្នាក់ចង់អោយគ្រឿងញៀនមកត្រួតត្រាលើជីវិត រាងកាយ និង អារម្មណ៍របស់យើងទេ ។ ប៉ុន្តែជាអកុសល យើងនៅតែឃើញមានមនុស្សមួយចំនួនកំពុងត្រូវបានគ្រឿងញៀនត្រួតត្រាជីវិត រាងកាយ និង អារម្មណ៍របស់គេដែលជាហេតុនាំអោយគេប្រព្រឹត្តអំពើអបាយមុខ និងអំពើល្មើសច្បាប់នានា នាំអោយមានអសន្តិសុខនៅក្នុងសង្គមគ្រួសារ សហគមន៍មូលដ្ឋាន និងប្រទេសជាតិទាំងមូល។ យើងឃើញថានៅពេលដែលគ្រឿងញៀនបានចូលទៅដល់សង្គមគ្រួសារ សហគមន៍ណាមួយហើយ គ្រួសារ សហគមន៍នោះនឹងគ្មានសុវត្ថិភាព គ្មានសន្តិសុខ និង ការអភិវឌ្ឍន៍ទេ។ គ្រឿងញៀននឹងត្រួតត្រារាងកាយនិងអារម្មណ៍របស់អ្នកប្រើប្រាស់វា។

គ្រឿងញៀន និងបទល្មើសផ្សេងៗនឹងលុកលុយត្រួតត្រាសហគមន៍របស់លោកអ្នកទាំងមូលតែម្តង ។ ដូច នេះដើម្បី **អោយជីវិតយើង សហគមន៍យើង គ្មានគ្រឿងញៀន** លុះត្រាតែយើងគ្រប់គ្នាត្រូវ ឈរលើស្មារតីទទួលខុសត្រូវរួមគ្នា ដោយចាត់ទុកថាបញ្ហាគ្រឿងញៀនគឺជាបញ្ហារបស់យើងទាំងអស់គ្នា ដែលត្រូវដោះស្រាយមិនមែនជាបញ្ហារបស់បុគ្គលណាម្នាក់ គ្រួសារណាមួយឬសហគមន៍ណាមួយនោះទេ។ ជាមួយគ្នានេះដែរ យើងក៏មិនត្រូវរើសអើងចំពោះអ្នកដែលធ្លាប់បានធ្លាក់ខ្លួនទៅក្នុងអន្ទាក់គ្រឿងញៀន ហើយបានកែប្រែខ្លួនមកចូលរួមរស់ជាមួយគ្រួសារសង្គមវិញឡើយ ។ យើងត្រូវលើកទឹកចិត្តពួកគេដោយ ការសរសើរ ការជួយគាំទ្រនូវការបណ្តុះបណ្តាលជំនាញនានា និង ការផ្តល់ការងារស្របតាមសមត្ថភាព របស់ពួកគេ ។ ខ្ញុំគិតថា ដើម្បីធ្វើដូចនេះ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ វត្តអារាម សង្គមស៊ីវិលនានា ត្រូវចាប់ផ្តើមចលនានៅតាមមូលដ្ឋានដែលរងផលប៉ះពាល់ដោយផ្ទាល់ចំពោះបញ្ហាគ្រឿងញៀន អោយ មានការយល់ដឹងជាសារធារណៈអំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន ហើយគៀងគរអោយមាន ការចូលរួមពីបុគ្គលដែលជាអតីតអ្នកប្រើប្រាស់គ្រឿងញៀន ក្រុមគ្រួសារ សហគមន៍មូលដ្ឋាន ក្នុងការ បង្ការ និងទប់ស្កាត់បញ្ហាគ្រឿងញៀននៅតាមសហគមន៍របស់គេ ។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមបញ្ជាក់ឡើងវិញសារជាថ្មីប្រាប់ដល់ក្មួយៗជាយុវជនទាំងអស់ថា **គ្រឿងញៀន** វាមិនមែនជាថ្នាំឬចំណីអាហារ ហើយក៏មិនមែនជាល្បែងកំសាន្តដែលក្មួយៗ ត្រូវសាក ល្បងនោះដែរ ផ្ទុយទៅវិញវាជាសារធាតុមួយដែលបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរបើខ្វះការប្រុងប្រយ័ត្ន ហើយនៅទីបញ្ចប់វានឹងបណ្តាលឱ្យក្មួយៗធ្លាក់ខ្លួនញៀនយ៉ាងខ្លាំង ដែលពិបាកនឹងបញ្ឈប់បាន ។ មាន យុវជនមួយចំនួនបានដឹងអំពីឥទ្ធិពលអាក្រក់នៃគ្រឿងញៀន បន្ទាប់ពីបានសាកល្បងប្រើវា ហើយមិនអាច បញ្ឈប់វិញបាន ។ ត្រូវចងចាំថាគ្រឿងញៀនមិនអាចសាកល្បងបានទេ ។ ប្រសិនបើក្មួយៗសាកល្បងវា រូបក្មួយផ្ទាល់ គ្រួសារ មិត្តភ័ក្ត សហគមន៍ និង ប្រទេសជាតិរបស់ក្មួយៗ នឹងទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរ ហើយឈ្មួញគ្រឿងញៀន គឺជាអ្នកទទួលជោគជ័យព្រោះគេបានចំណេញពីទុក្ខសោករបស់ក្មួយៗ និងពី សង្គមជាតិរបស់យើង ។

តើយើងបណ្តោយអោយឈ្មួញគ្រឿងញៀន កេងចំណេញពីភាពទុក្ខសោកវេទនារបស់យើងឬ? តើយើងបណ្តោយអោយពួកគេបង្កអោយមានអសន្តិសុខក្នុងសហគមន៍ និង បំផ្លាញដល់សេចក្តីសុខសាន្ត និងភាពថ្លៃថ្នូរបស់យើងឬ ? ហើយតើធ្វើដូចម្តេចដើម្បីអោយខ្លួនយើង សហគមន៍យើងគ្មានគ្រឿង ញៀន? វាមិនមានការលំបាកទេសំរាប់ការដោះស្រាយបញ្ហានេះបើសិនប្រជាជនរស់នៅក្នុងសហគមន៍ យល់ច្បាស់ពីបញ្ហាគ្រឿងញៀន និងចូលរួមកំលាំងគ្នាដើម្បីចែករំលែកនូវការទទួលខុសត្រូវក្នុងការធ្វើ

អោយសហគមន៍គ្មានគ្រឿងញៀន ។ វិធីមួយដែលខ្ញុំគិតថានឹងអាចទទួលជោគជ័យ គឺនៅតាមសហគមន៍ត្រូវរៀបចំអោយមានជាបណ្តាញប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយធ្វើយ៉ាងណាទប់ស្កាត់កុំអោយយុវជនរបស់យើងទៅប្រើប្រាស់គ្រឿងញៀន ហើយកំលាំងអនុវត្តច្បាប់របស់រាជរដ្ឋាភិបាលទប់ស្កាត់ បង្ក្រាបការផលិត ការចរាចរ និង ការចែកចាយគ្រឿងញៀន ។ ជាមួយគ្នានេះដែរ នៅតាមសហគមន៍ដែលមានអ្នកញៀនគ្រឿងញៀនច្រើន យើងត្រូវរួបរួមគ្នាជួយអប់រំពួកគេអោយឈប់ប្រើប្រាស់គ្រឿងញៀន និងជួយអន្តរាគមន៍ពួកគេអោយចូលខ្លួនទៅធ្វើការព្យាបាលផ្តាច់គ្រឿងញៀន អោយបានគ្រប់ៗគ្នា ទន្ទឹមនឹងនេះ នៅពេលដែលពួកគេត្រឡប់មកនៅក្នុងសហគមន៍វិញមិនត្រូវមានការរើសអើងទេ ត្រូវលើកទឹកចិត្តគេ អូសទាញគេអោយជួយពន្យល់ដល់អ្នកប្រើប្រាស់គ្រឿងញៀនតទៅទៀត អោយឈប់ប្រើប្រាស់គ្រឿងញៀន ។ ចំពោះបញ្ហានេះ ខ្ញុំក៏សូមអំពាវនាវដល់អង្គការក្រៅរដ្ឋាភិបាលជាតិ និង អន្តរជាតិនានាសូមចូលរួមដោយផ្ទាល់ជាមួយសហគមន៍មូលដ្ឋាន ដើម្បីដោះស្រាយបញ្ហានេះ ។

*ព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រី ជនរួមជាតិ ក្មួយៗសិស្សានុសិស្ស ទាំងអស់*

ដូចដែលខ្ញុំបានជំរាបជូនពីខាងដើមហើយថា ខេត្តបាត់ដំបងត្រូវបានថ្នាក់ជាតិជ្រើសរើសធ្វើជាខេត្តដកពិសោធន៍សំរាប់ការងារផែនការប្រៀបសមរភូមិ ។ ដូចនេះដើម្បីសំរេចបាននូវផែនការនេះ និងដើម្បីអោយស្របតាមប្រធានបទប្រយុទ្ធប្រឆាំងគ្រឿងញៀននៅឆ្នាំនេះ ខ្ញុំសូមផ្តើមគំនិតខ្លះដូចតទៅ:

១. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ទន្ទឹមនឹងសកម្មភាពដែលខ្លួនធ្វើប្រចាំថ្ងៃ ត្រូវបង្កើតយន្តការតាមដានការងារត្រួតពិនិត្យគ្រឿងញៀន អោយបានជាប្រចាំ ដូចជាការងារក្តាប់ស្ថិតិទិន្នន័យអ្នកប្រើប្រាស់ អ្នកជួញដូរ ចរាចរ គ្រឿងញៀន និង ការអប់រំផ្សព្វផ្សាយអោយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន និង ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

២. ដើម្បីអនុវត្តផែនការប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត-ក្រុង ត្រូវរៀចំយន្តការ អោយមានការចូលរួមពីសហគមន៍ដើម្បីគាំទ្រដល់សកម្មភាពខាងលើតាមរយៈការបរិចាកធនធានផ្ទាល់ខ្លួនរបស់បុគ្គល គ្រួសារ សង្គម វត្តអារាមដើម្បីជួយគាំទ្រដល់ដំណើរការអប់រំផ្សព្វផ្សាយ ការព្យាបាល និង ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ ។

៣. ដោយឡែកគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តបាត់ដំបង ក្រៅពីចំណុចខាងលើ ត្រូវរៀបចំអោយមានការប្រឡងប្រណាំងក្នុងការធ្វើអោយសហគមន៍គ្មានគ្រឿងញៀន ដោយរៀបចំអោយមានការប្រឡងប្រណាំងក្នុងការសរសេរអត្ថបទ និង គូររូបភាពលើប្រធានបទដូចខាងក្រោម:

- ធ្វើយ៉ាងណាដើម្បីអោយភូមិ/ឃុំគ្មានគ្រឿងញៀន ?
- តួនាទីគ្រូបង្រៀនក្នុងការជួយអប់រំកុំអោយមានការប្រើគ្រឿងញៀន និង ក្នុងការជួយដល់អ្នកដែលធ្លាក់ខ្លួនប្រើគ្រឿងញៀននិងក្រុមគ្រួសាររបស់អ្នកប្រើគ្រឿងញៀន
- តួនាទីសាលាក្នុងការគៀងគរការគាំទ្រថវិកា និង បច្ចេកទេសពីអាជីវករ ពាណិជ្ជករ ក្នុងសកម្មភាពអប់រំបង្ការគ្រឿងញៀនរបស់សិស្សនៅតាមសាលា
- ការគូររូបភាពរបស់សិស្សអនុវិទ្យាល័យលើប្រធានបទតើគ្រឿងញៀនត្រួតត្រាជីវិតយើងឬ? ជីវិតយើង សហគមន៍យើង គ្មានគ្រឿងញៀន ។

ការប្រឡងប្រណាំងនេះគឺត្រូវចាប់ផ្តើមផ្សព្វផ្សាយពីថ្ងៃនេះទៅ ហើយអ្នកដែលមានទឹកដៃឆ្នើមនឹងត្រូវទទួលបានរង្វាន់ពីគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត និង អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

*ព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រី ភ្ញៀវជាតិ និង អន្តរជាតិ ក្មួយៗយុវជនទាំងអស់*

ជាថ្មីម្តងទៀត ក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងនូវការកោតសរសើ និង អំណរគុណចំពោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ប្រទេសជាមិត្ត អង្គការជាតិ និង អន្តរជាតិនានា និង ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ដែលបានចូលរួមចំណែកគាំទ្រក្នុងសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀនរបស់កម្ពុជា និង សូមប្រគេនពរជូនព្រះតេជគុណគ្រប់ព្រះអង្គ និង ជូនពរដល់បងប្អូនជនរួមជាតិ និងក្មួយៗ កុមារា កុមារី យុវជន យុវនារី សិស្សានុសិស្ស ភ្ញៀវជាតិ និង អន្តរជាតិទាំងអស់ សូមអោយជួបប្រទះតែនឹងសេចក្តីសុខគ្រប់ប្រការ ជានិច្ចនិរន្ត ។

**សូមអរគុណ**